ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០២៤ សហវ.ភរស.សសហក

# សារាចរណែនាំ

## ស្តីពី

## ការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុប ការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៤

យោងមាត្រា១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនាឆ្នាំ២០២៣, មាត្រា១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១, ប្រការ៣២ និងប្រការ៣៣ នៃប្រកាសលេខ ២០៣ប្រក.សហវ.ថ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩, មាត្រា២៧ នៃអនុក្រឹត្យលេខ ១៧២ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ និងមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេសស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤ ដូចខាងក្រោម÷

១.អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក មេឃុំ ដែលជាអាណាប័កដើមខ្សែ និងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ប្រធានអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស អភិបាលនៃគណៈអភិបាលខណ្ឌ ចៅសង្កាត់ ដែលជាអាណាប័កផ្ទេរសិទ្ធិ ត្រូវខិតខំជំរុញការប្រមូលប្រាក់ចំណូលសារពើពន្ធ និងប្រាក់ចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលសាមី និងរៀបចំសលាកបត្របង់ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ **យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។** ប្រសិនបើមានការយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគាររាជធានី ខេត្ត ត្រូវកត់ត្រាចូលជាចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ទីរសុខាភិបាលរាជធានី ខេត្ត និងអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស **សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៥។**

២. ការស្នើសុំឧបត្ថម្ភគុល្យភាពថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **យ៉ាងយូរត្រឹមថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤។**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

៣. ការធ្វើនិយ័តភាពឥណទានថវិកា និងការកែតម្រូវថវិកា÷

- ការធ្វើនិយ័តភាពឥណទានថវិកាដែលត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **យ៉ាងយូរត្រឹម ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤**។

- ការធ្វើនិយ័តភាពឥណទានថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវស្នើសុំការអនុញ្ញាតពីរដ្ឋបាលខេត្តសាមីជាអ្នកសម្រេច រដ្ឋបាលក្រុង ស្រុកត្រូវបញ្ជូនសំណុំលិខិតស្នើសុំមករដ្ឋបាលខេត្ត**យ៉ាងយូរត្រឹម ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤**។

- ការកែតម្រូវថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមករដ្ឋបាលរាជធានី ខេត្តសាមី **យ៉ាងយូរត្រឹមថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤**។

៤ ប្រាក់រជ្ជទេយ្យបុរេប្រទាន ប្រាក់ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងប្រាក់បុរេប្រទាន ÷

- រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិនិយ័តកម្មសម្រាប់ការទូទាត់ និងបើកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទានចុងក្រោយបង្ហស់ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ **នៅវេលាម៉ោង ១១ និង៣០នាទី នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤**។ រជ្ជទេយ្យករបុរេប្រទានត្រូវរួតរះប្រមូលឯកសារ និងលិខិតយុត្តិការចំណាយ ស្នើសុំទូទាត់ឱ្យបានមុន **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**។

- រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិនិយ័តកម្មសម្រាប់ការទូទាត់ និងបើកសាច់ប្រាក់ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន(សម្រាប់ចំណាយប្រាក់បេសកកម្មក្នុងប្រទេស និងចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ) ចុងក្រោយបង្ហស់ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ **នៅវេលាម៉ោង ១១ និង៣០នាទី នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤**។ រជ្ជទេយ្យករបុរេប្រទានត្រូវរួតរះប្រមូលឯកសារ និងលិខិតយុត្តិការចំណាយ ស្នើសុំទូទាត់ឱ្យបានមុន **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**។

- រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលលិខិតបុរេប្រទានសម្រាប់ការបើកផ្តល់ប្រាក់បុរេប្រទានចុងក្រោយ (លើកលែងចំណាយបន្ទុកបុគ្គលិក) **នៅវេលាម៉ោង ១៧ និង៣០នាទី ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤**។ ការទូទាត់ប្រាក់បុរេប្រទាននេះត្រូវរួតរះប្រមូលឯកសារស្នើសុំការទូទាត់ឱ្យបានមុន**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**ជាកំហិត។

- ចំពោះប្រាក់រជ្ជទេយ្យបុរេប្រទាន ប្រាក់ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន(សម្រាប់ចំណាយប្រាក់បេសកកម្មក្នុងប្រទេស និងចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំ) និងប្រាក់បុរេប្រទានដែលរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានចំណាយនៅសល់ត្រូវយកមកបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្តនៅធនាគារមិនឱ្យហួស **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី។

-ចំពោះប្រាក់ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងលេខ៣៨៥ សហវ.ប្រក.អថ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤។

៥. ចំពោះការបង់សំណែសចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្រោយថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទឆ្នាំ២០២៤ ត្រូវបានចាត់ទុកជាចំណូលថវិកានៃការិយបរិច្ឆេទសម្រាប់ឆ្នាំ២០២៥ ដោយកត់ត្រាក្នុង**អនុគណនី៧៦៩៨១ (ផលពីហិរញ្ញវត្ថុផ្សេងៗ)**។

៦. រតនាគាររាជធានី ខេត្ត ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ **នៅម៉ោង ១៧ និង៣០នាទី ថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២៤។** ដូច្នេះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយ ដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ (អាណត្តិបើកប្រាក់ ទូទាត់ត្រង់ និងអាណត្តិនិយ័តកម្ម) និង/ឬ ប្រតិបត្តិការចំណាយ(Voucher) ក្នុងប្រព័ន្ធ FMIS ឆ្លងទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ (រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ពុំចាំបាច់ឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ) រួចបញ្ជូនទៅរតនាគាររាជធានី ខេត្ត បានមុន **ម៉ោង ១៧ និង៣០នាទី ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។**

៧. អំពីការទូទាត់ថវិកាប្រាក់រង្វាន់ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរួតរះបោះផ្សាយអាណត្តិនិយ័តកម្ម សម្រាប់ការអនុវត្តនីតិវិធីទូទាត់ថវិកាប្រាក់រង្វាន់ដែលបានដកមុន និងធ្វើសលាកបត្របង្វែរចំណូលចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នូវចំណូលប្រមូលបាននៅរដ្ឋបាលរាជធានី ខេត្ត (អង្គភាពច្រកចេញចូលតែមួយ និងមន្ទីរជំនាញ) រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ក្នុងឆ្នាំ២០២៤ និងក្នុងឆ្នាំ២០២៣ ដែលនៅសេសសល់ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់បានទូទាត់ ហើយនឹងត្រូវបញ្ជូនមករតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹម **ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៥។**

៨. អំពីអតិរេកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ÷

- រដ្ឋបាលរាជធានី ខេត្ត ត្រូវរួតរះរៀបចំរបាយការណ៍អនុវត្តចំណូល ចំណាយថវិកាដើម្បីធ្វើការផ្ទៀងផ្ទាត់តួលេខជាមួយរតនាគាររាជធានី ខេត្ត។ ករណីការអនុវត្តថវិកាមានអតិរេក រតនាគាររាជធានី ខេត្ត ត្រូវជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំលិខិតស្នើសុំផ្ទេរតួលេខអតិរេកថវិកាទៅគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានី ខេត្ត) នៅរតនាគារកណ្តាល **យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥** ហើយតួលេខអតិរេកថវិកាត្រូវកត់ត្រានៅ**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។**

- ការគណនាការអនុវត្តចំណូល ចំណាយថវិកា របស់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល÷ គណនេយ្យករថវិការាជធានី ខេត្ត ត្រូវគណនារកតួលេខលម្អៀងរវាងចំណូលថវិកាឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ(អនុគណនី ៧៥០១៦) និងសរុបគណនី អនុគណនីចំណាយថវិកា(ថ្នាក់៦)។ ចំនួនទឹកប្រាក់លម្អៀងនៃការអនុវត្តថវិកា ត្រូវអនុវត្តនីតិវិធីការបង់សំណែសចំណាយតាមខ្លឹមសារនៃសារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីកិច្ចបញ្ជិកាគណនេយ្យលើការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល។ គណនេយ្យករថវិការាជធានី ខេត្ត ត្រូវជូនដំណឹងទៅមន្ទីរសុខាភិបាលរាជធានី ខេត្ត និងចម្លងជូនរដ្ឋបាលរាជធានី ខេត្ត នូវចំនួនទឹកប្រាក់ដែលបានបន្ថយចំណូលថវិកា។

- ចំពោះអតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក មានប្រភពពីថវិការដ្ឋ ចំណូលផ្ទាល់ ថវិកាផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន និងថវិកាពីដៃគូអភិវឌ្ឍន៍ រតនាគាររាជធានី ខេត្ត ត្រូវជូនដំណឹងទៅ រដ្ឋបាលក្រុង ស្រុក ដើម្បីរៀបចំលិខិតស្នើសុំផ្ទេរតួលេខអតិរេកថវិកាទៅគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលក្រុង ស្រុក) នៅរតនាគារថ្នាក់កណ្តាល**យ៉ាងយូរត្រឹម ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥** ហើយតួលេខអតិរេកថវិកាត្រូវកត់ត្រានៅ**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។**

-ការបង់សំណែសចំណាយនៃថវិកាអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ÷ គណនេយ្យករថវិកាក្រុង ស្រុក ខណ្ឌ ត្រូវគណនារកទឹកប្រាក់លម្អៀងរវាងចំណូលថវិកាឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់

លក្ខខណ្ឌ(អនុគណនី ៧៥០១៦) និងទឹកប្រាក់ចំណាយសរុបគណនី អនុគណនីចំណាយថវិកា(ថ្នាក់៦) របស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ។ ចំនួនទឹកប្រាក់លម្អៀងនៃការអនុវត្តថវិកា ត្រូវអនុវត្តនីតិវិធីការបង់សំណែសចំណាយ តាមខ្លឹមសារនៃសារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ រហូតមានសារាចរណែនាំថ្មីមកជំនួស។ គណនេយ្យករថវិកាក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក/ការិយាល័យផែនការ និងហិរញ្ញវត្ថុខណ្ឌ នូវចំនួនទឹកប្រាក់ដែលបានបន្ថយចំណូលថវិកា។ សម្រាប់រដ្ឋបាលខណ្ឌ ត្រូវចម្លងជូនរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីជាមូលដ្ឋានកត់ត្រាបន្ថយចំណូល ចំណាយតាមតួលេខនៃការអនុវត្តជាក់ស្តែង។

- ចំពោះអតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ មានប្រភពពីថវិការដ្ឋ ចំណូលផ្ទាល់ ថវិកាផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន និងថវិកាពីដៃគូអភិវឌ្ឍន៍ រតនាគាររាជធានី ខេត្ត ត្រូវជូនដំណឹងដល់រដ្ឋបាលឃុំ សង្កាត់ អំពីតួលេខថវិកា សម្រាប់ប្រើប្រាស់ទៅឆ្នាំខាងមុខ។

- ដោយឡែកអតិរេកថវិកាសង្កាត់ចំណុះរដ្ឋបាលរាជធានី និងសង្កាត់ចំណុះរដ្ឋបាលក្រុង មិនត្រូវបញ្ចូលទៅក្នុងអតិរេកថវិការបស់រដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងសាមីឡើយ។ ប៉ុន្តែចំពោះអតិរេកថវិការបស់រដ្ឋបាលខណ្ឌ (បើមាន) ត្រូវបញ្ចូលទៅក្នុងអតិរេកថវិការបស់រដ្ឋបាលរាជធានី។

៩. ប្រតិបត្តិការនិយ័តកម្មនៃរតនាគាររាជធានី ខេត្ត សម្រាប់ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ឆ្នាំ២០២៤ ត្រូវបន្តរហូតដល់ **ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥** ដែលទាក់ទងទៅនឹង÷

- ការកត់ត្រាជាស្ថាពរនៃចំណូលចំណាយ
- ប្រតិបត្តិការកែតម្រូវលេខនាគណនេយ្យខុស
- ប្រតិបត្តិការបូកសរុបរបស់គណនេយ្យករសាធារណៈ។

**១០. ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥** ទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ការិយាល័យផែនការ និងហិរញ្ញវត្ថុរបស់រដ្ឋបាលខណ្ឌ និងជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ត្រូវដំណើរការបូកសរុប និងផ្ទៀងផ្ទាត់តួលេខ នៃការអនុវត្តចំណូលចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ឆ្នាំ២០២៤ ជាមួយរតនាគាររាជធានី ខេត្ត រួចផ្ញើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានមុន **ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥**។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលសាមីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១" និង "ខ១", "ក២" និង "ខ២", "ក៣" និង "ខ៣"។

- មន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយប្រចាំឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១.១" និង "ខ១.១"។

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក/ការិយាល័យផែនការ និងហិរញ្ញវត្ថុខណ្ឌ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាប្រចាំឆ្នាំ របស់មុខងារការអប់រំកុមារតូច

ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដូចមានគំរូតារាងឧបសម្ព័ន្ធ“ក២.១”និង “ខ២.១”។

- រដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលរាជធានី និងរដ្ឋបាលសង្កាត់ចំណុះរដ្ឋបាលក្រុង ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមករដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងដើម្បីធ្វើការបូកសរុប។

- រដ្ឋបាលខណ្ឌ ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមករដ្ឋបាលរាជធានីដើម្បីធ្វើការបូកសរុប។

- មន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមករដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុប។

- រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលខណ្ឌដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៤” និង “ខ៤”។

- រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលការអនុវត្តចំណូលថវិការបស់រដ្ឋបាលរាជធានី, សរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលខណ្ឌ និងសរុបការអនុវត្តចំណូល ចំណាយថវិការបស់មន្ទីរសុខាភិបាលរាជធានី ដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៥” និង “ខ៥”ជូនភ្ជាប់មកជាមួយ។

- រដ្ឋបាលខេត្ត ត្រូវបូកបញ្ចូលការអនុវត្តចំណូលថវិការបស់រដ្ឋបាលខេត្ត និងសរុបការអនុវត្តចំណូល ចំណាយថវិការបស់មន្ទីរសុខាភិបាលខេត្ត ដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៥.១” និង “ខ៥.១” ជូនភ្ជាប់មកជាមួយ។

- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបូកបញ្ចូលការអនុវត្តចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសរុបការអនុវត្តចំណូល ចំណាយថវិការបស់ មុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដូចមានគំរូតារាងឧបសម្ព័ន្ធ “ក២.២” និង “ខ២.២”ជូនភ្ជាប់មកជាមួយ។

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីធ្វើការបូកសរុបដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៧” និង “ខ៧” ជូនភ្ជាប់មកជាមួយ។

- រតនាគាររាជធានី ខេត្ត ត្រូវបញ្ជូនរបាយការណ៍ស្តីពីការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានធ្វើការបូកសរុបការបិទបញ្ជីចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៦” និង “ខ៦” និង “ក៧” និង“ខ៧” ជូនភ្ជាប់មកជាមួយ។

- មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនរបាយការណ៍ស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំ និងឯកសារពាក់ព័ន្ធទាំងអស់មករតនាគាររាជធានី ខេត្ត ដើម្បីធ្វើការផ្ទៀងផ្ទាត់បានត្រឹមត្រូវ រួចបញ្ជូនទៅអភិបាល នៃគណៈអភិបាលខេត្ត ដើម្បីបញ្ជាក់នីត្យានុកូលភាព។

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍គម្រោងអភិវឌ្ឍន៍នៅមូលដ្ឋានសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៨” ជូនភ្ជាប់មកជាមួយ។

- រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ត្រូវបូកសរុបការអនុវត្តចំណូល ចំណាយ និងអតិរេកថវិកាដូចមានគំរូតារាងឧបសម្ព័ន្ធ “ក៩” ជូនភ្ជាប់មកជាមួយ។

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍ពិតានចំនួនបុគ្គលិកស៊ីវិល សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ដូចមានគំរូតារាងឧបសម្ព័ន្ធ "ក១០" ជូនភ្ជាប់មកជាមួយ។

១១. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ត្រូវរៀបចំរបាយការណ៍ស្ដីពីការអនុវត្តថវិកាដោយភ្ជាប់មកនូវរបាយការណ៍បូកសរុបចំណូល ចំណាយថវិកា ដាក់ឆ្លងអង្គប្រជុំអនុម័តពីក្រុមប្រឹក្សារបស់រដ្ឋបាលសាមី។ ក្រោយពីក្រុមប្រឹក្សាបានអនុម័តលើរបាយការណ៍បិទបញ្ជីថវិកាប្រចាំឆ្នាំ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ត្រូវអនុវត្តដូចខាងក្រោម÷

- ចំពោះអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើរបាយការណ៍ស្ដីពីការបិទបញ្ជីថវិកាដោយមានភ្ជាប់នូវរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកា (ច្បាប់ដើម) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០១ច្បាប់ និងក្រសួងមហាផ្ទៃចំនួន ០១ច្បាប់។
- របាយការណ៍បិទបញ្ជីថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ) យ៉ាងយូរបំផុតត្រឹម **ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥** ដើម្បីធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សម្រេចទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដាក់បញ្ចូលទៅក្នុងជំពូកមួយនៃសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងរតនាគាររាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់សហការ និងអនុវត្តសារាចរនេះបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

រាជធានី ខេត្ត.........

លេខកូដ...............

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## តារាងបូកសរុបចំណូលថវិការដ្ឋបាលរាជធានី ខេត្ត.....

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក១

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | % ច្បាប់ | លើស(+)/ ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |
| សរុបរួម | | | | | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |

រាជធានី ខេត្ត.........

លេខកូដ...............

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងបូកសរុបចំណាយថវិការដ្ឋបាលរាជធានី ខេត្ត.....

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷៦១

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | % ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=1+2+3-4 | 6 | 7=6/5 | 8=6-5 | |
| | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត.........

មន្ទីរសុខាភិបាលរាជធានី ខេត្ត.....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិកាមន្ទីរសុខាភិបាលរាជធានី ខេត្ត.....

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក១.១

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | %ច្បាប់ | លើស(+)/ ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |
| សរុបរួម | | | | | | | | |

ស.អ.ហ

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត...... | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |

រាជធានី ខេត្ត.........

មន្ទីរសុខាភិបាលរាជធានី ខេត្ត..........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណាយថវិកាមន្ទីរសុខាភិបាលរាជធានី ខេត្ត.....
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷១១.១

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | | | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | កើន | | | | | | | | | |
| | | | | | ចលនាផ្ទៃក្នុង | ឥណទានមិនបានគ្រោងទុក | បំពេញបន្ថែម | សរុប | ថយ | | | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=2+3+4 | 6 | 7=1+5-6 | 8 | 9=8/7 | 10=8-7 | |
| | | | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និងត្រា<br>ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត...... | ហត្ថលេខា និងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ហត្ថលេខា និងត្រា<br>ប្រធានរតនាគាររាជធានី ខេត្ត | ហត្ថលេខា<br>អ្នកធ្វើតារាង |

រាជធានី ខេត្ត.........

ក្រុង ស្រុក ខណ្ឌ.....

លេខកូដ..............

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាល ក្រុង ស្រុក ខណ្ឌ

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក២

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | % ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |
| សរុបរួម | | | | | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |

រាជធានី ខេត្ត.........
ក្រុង ស្រុក ខណ្ឌ.....
លេខកូដ..............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណាយថវិការដ្ឋបាល ក្រុង ស្រុក ខណ្ឌ
## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷១២

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=1+2+3-4 | 6 | 7=6/5 | 8=6-5 | |
| | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត.........
ក្រុង ស្រុក ខណ្ឌ .....
លេខកូដ..............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិកាមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក២.១
ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | % ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |
| សរុបរួម | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលក្រុង ស្រុក

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត.........
ក្រុង ស្រុក ខណ្ឌ .....
លេខកូដ.........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងបូកសរុបចំណាយថវិកាមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ខ២.១

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | ឥណទាន អនុញ្ញាត | អនុវត្ត ជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=1+2+3-4 | 6 | 7=6/5 | 8=6-5 | |
| | | | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |

រាជធានី ខេត្ត........
ក្រុង ស្រុក ខណ្ឌ .....
លេខកូដ.............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ... និងមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក២.២
ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | ក្រុង ស្រុក ខណ្ឌ | មុខងារអប់រំ | សរុបរួម | ក្រុង ស្រុក ខណ្ឌ | មុខងារអប់រំ | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1=2+3 | 2 | 3 | 4=5+6 | 5 | 6 | 7=4/1 | 8=4-1 | |
| | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត.........

ក្រុង ស្រុក ខណ្ឌ .....

លេខកូដ.........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណាយថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ... និងមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ខ២.២

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | ឥណទានអនុញ្ញាត | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | ក្រុង ស្រុក ខណ្ឌ | មុខងារអប់រំ | សរុបរួម | ក្រុង ស្រុក ខណ្ឌ | មុខងារអប់រំ | សរុបរួម | ក្រុង ស្រុក ខណ្ឌ | មុខងារអប់រំ | |
| | | | | 1=2+3 | 2 | 3 | 4=5+6 | 5 | 6 | 7=8+9 | 8 | 9 | 10=7/4 |
| | | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

ហត្ថលេខា និងត្រា

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានីភ្នំពេញ

ហត្ថលេខា

អ្នកធ្វើតារាង

រាជធានី ខេត្ត.........
ក្រុង ស្រុក ខណ្ឌ.....
ឃុំ សង្កាត់............
លេខកូដ..............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាលឃុំ សង្កាត់
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៣
ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | % ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |
| **សរុបរួម** | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា
មេឃុំ ចៅសង្កាត់

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត.........

ក្រុង ស្រុក ខណ្ឌ.....

ឃុំ សង្កាត់...........

លេខកូដ.............

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងបូកសរុបចំណាយថវិការដ្ឋបាលឃុំ សង្កាត់

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷១៣

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | ឥណទាន | អនុវត្ត | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | អនុញ្ញាត | ជាក់ស្តែង | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=1+2+3-4 | 6 | 7=6/5 | 8=6-5 | |
| | | | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ហត្ថលេខា និងត្រា

មេឃុំ ចៅសង្កាត់

ហត្ថលេខា និងត្រា

ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា

អ្នកធ្វើតារាង

រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាលខណ្ឌចំណុះរដ្ឋបាលរាជធានី

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៤

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលនៃគណៈអភិបាលរាជធានី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី | អ្នកធ្វើតារាង |

រាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងបូកសរុបចំណាយថវិការដ្ឋបាលខណ្ឌចំណុះរដ្ឋបាលរាជធានី

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷១៤

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | ឥណទាន អនុញ្ញាត | អនុវត្ត ជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=1+2+3-4 | 6 | 7=6/5 | 8=6-5 | |
| | | | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
| អភិបាលនៃគណៈអភិបាលរាជធានី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី | អ្នកធ្វើតារាង |

រដ្ឋបាលរាជធានីភ្នំពេញ

លេខកូដ................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាលរាជធានីភ្នំពេញ មន្ទីរសុខាភិបាល និងខណ្ឌចំណុះ

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៥

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | អនុវត្តជាក់ស្តែង | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី | មន្ទីរសុខាភិបាល | សរុបខណ្ឌ | សរុបរួម | រាជធានី | មន្ទីរសុខាភិបាល | សរុបខណ្ឌ | |
| | | | | 1=2+3+4 | 2 | 3 | 4 | 5=6+7+8 | 6 | 7 | 8 | 9=5/1 |
| | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានីភ្នំពេញ

ហត្ថលេខា
អ្នកធ្វើតារាង

រដ្ឋបាលរាជធានីភ្នំពេញ

លេខកូដ.................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តារាងឧបសម្ព័ន្ធ÷២៥

# តារាងបូកសរុបចំណាយថវិការដ្ឋបាលរាជធានីភ្នំពេញ មន្ទីរសុខាភិបាល និងខណ្ឌចំណុះ
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | | ឥណទានអនុញ្ញាត | | | | អនុវត្តជាក់ស្តែង | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី | មន្ទីរសុខាភិបាល | សរុបខណ្ឌ | សរុបរួម | រាជធានី | មន្ទីរសុខាភិបាល | សរុបខណ្ឌ | សរុបរួម | រាជធានី | មន្ទីរសុខាភិបាល | សរុបខណ្ឌ | |
| | | | | 1=2+3+4 | 2 | 3 | 4 | 5=6+7+8 | 6 | 7 | 8 | 9=10+11+12 | 10 | 11 | 12 | 13=9/5 |
| | | | | | | | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានីភ្នំពេញ

ហត្ថលេខា
អ្នកធ្វើតារាង

រដ្ឋបាលខេត្ត.......

លេខកូដ.................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងបូកសរុបចំណូលថវិការដ្ឋបាលខេត្ត... និងមន្ទីរសុខាភិបាល

តារាងឧបសម្ព័ន្ធ÷ក៥.១

## សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | អនុវត្តជាក់ស្ដែង | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | ខេត្ត | មន្ទីរសុខាភិបាល | សរុបរួម | ខេត្ត | មន្ទីរសុខាភិបាល | |
| | | | | 1=2+3 | 2 | 3 | 4=5+6 | 5 | 6 | 7=4/1 |
| | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
| អភិបាលនៃគណៈអភិបាលខេត្ត...... | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគារខេត្ត.... | អ្នកធ្វើតារាង |

រដ្ឋបាលខេត្ត......

លេខកូដ.................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តារាងបូកសរុបចំណាយថវិការដ្ឋបាលខេត្ត... និងមន្ទីរសុខាភិបាល

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ខ៥.១

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | ឥណទានអនុញ្ញាត | | | អនុវត្តជាក់ស្តែង | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | ខេត្ត | មន្ទីរសុខាភិបាល | សរុបរួម | ខេត្ត | មន្ទីរសុខាភិបាល | សរុបរួម | ខេត្ត | មន្ទីរសុខាភិបាល | |
| | | | | 1=2+3 | 2 | 3 | 4=5+6 | 5 | 6 | 7=8+9 | 8 | 9 | 10=7/4 |
| | | | | | | | | | | | | | |
| **សរុបរួម** | | | | | | | | | | | | | |

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលខេត្ត.....

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគារខេត្ត.......

ហត្ថលេខា
អ្នកធ្វើតារាង

រាជធានី ខេត្ត.........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាលឃុំ សង្កាត់

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៦

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | % ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3=2/1 | 4=2-1 | |
| | | | | | | | | |
| **សរុបរួម** | | | | | | | | |

| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា |
|---|---|---|
| ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធានរតនាគាររាជធានី ខេត្ត | អ្នកធ្វើតារាង |
| | | (មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត) |

រាជធានី ខេត្ត.........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណាយថវិការដ្ឋបាលឃុំ សង្កាត់

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ខ៦

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | ចលនាឥណទាន | | | ឥណទានអនុញ្ញាត | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ថែម | កើន | ថយ | | | %ច្បាប់ | លើស(+)/ខ្វះ(-) | |
| | | | | 1 | 2 | 3 | 4 | 5=1+2+3-4 | 6 | 7=6/5 | 8=6-5 | |
| | | | | | | | | | | | | |
| សរុបរួម | | | | | | | | | | | | |

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង
(មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត)

រាជធានី ខេត្ត......

លេខកូដ...........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៧

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ច្បាប់ហិរញ្ញវត្ថុ | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុប ក្រុង | សរុបស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | សរុបរួម | រាជធានី ខេត្ត | សរុប ក្រុង | សរុបស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=7/1 |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង
(មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

រាជធានី ខេត្ត.........

លេខកូដ..............

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងបូកសរុបចំណាយថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷១៧

ឯកតា÷រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ | | | | | | ឥណទានអនុញ្ញាត | | | | | | អនុវត្តជាក់ស្តែង | | | | | | សមាមាត្រប្រៀបធៀប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុបស្រុក ខណ្ឌ | សរុប ឃុំ | សរុប សង្កាត់ | សរុបរួម | រាជធានី ខេត្ត | សរុបក្រុង | សរុបស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | សរុបរួម | រាជធានី ខេត្ត | សរុប ក្រុង | សរុបស្រុក ខណ្ឌ | សរុបឃុំ | សរុប សង្កាត់ | |
| | | | | 1=2+3+4+5+6 | 2 | 3 | 4 | 5 | 6 | 7=8+9+10+11+12 | 8 | 9 | 10 | 11 | 12 | 13=14+15+16+17+18 | 14 | 15 | 16 | 17 | 18 | 19=13/7 |
| | | | | | | | | | | | | | | | | | | | | | | |

ហត្ថលេខា និងត្រា
ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា
ប្រធានរតនាគាររាជធានី ខេត្ត

ហត្ថលេខា
អ្នកធ្វើតារាង
(មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

រាជធានី ខេត្ត.........

ក្រុង ស្រុក ...........

ឃុំ សង្កាត់...........

លេខកូដ..............

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងរបាយការណ៍គម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់..........................

## សម្រាប់គ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៨

ឯកតា÷រៀល

| ល.រ | លេខគម្រោង | ឈ្មោះគម្រោង | តម្លៃគម្រោង | គម្រោងថវិកាឆ្នាំ ២០២៤ | អនុវត្តជាក់ស្តែងឆ្នាំ២០២៤ | ផ្សេងៗ (អនុគណនី) |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ហត្ថលេខា និងត្រា

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

ហត្ថលេខា

អ្នកធ្វើតារាង

រាជធានី ខេត្ត........
ក្រុង ស្រុក...........
ឃុំ សង្កាត់...........
លេខកូដ.............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងសរុបចំណូល ចំណាយ និងអតិរេកថវិកា របស់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់............................

## សម្រាប់គ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក៩
ឯកតា÷រៀល

| ល.រ | ប្រភពថវិកា | សរុបចំណូល ឆ្នាំ២០២៤ | សរុបចំណាយ ឆ្នាំ២០២៤ | អតិរេកថវិកា ឆ្នាំ២០២៤ |
|---|---|---|---|---|
| | | 1 | 2 | 5=3+4 |
| ១ | មូលនិធិក្រុង ស្រុក/ឃុំ សង្កាត់, ចំណូលសារពើពន្ធបែងចែកពីរដ្ឋបាលរាជធានី ខេត្ត និង ចំណូលមិនមែនសារពើពន្ធ ឬចំណូលផ្ទាល់នៅមូលដ្ឋាន | | | |
| ២ | ថវិកាសេវាអនាម័យបរិស្ថាន | | | |
| ៣ | ថវិកាផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ | | | |
| ៤ | ថវិកាផ្ទេរមុខងាររបស់ក្រសួងបរិស្ថាន | | | |
| ៥ | ........................................................................................... | | | |
| ៦ | ........................................................................................... | | | |
| ៧ | ........................................................................................... | | | |
| ៨ | ........................................................................................... | | | |
| ៩ | ........................................................................................... | | | |
| សរុបរួម | | | | |

*សំគាល់÷ សម្រាប់រដ្ឋបាលឃុំ សង្កាត់ មិនមានការចុះហត្ថលេខាប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| | | | |
|---|---|---|---|
| ហត្ថលេខា និងត្រា<br>អភិបាលនៃគណៈអភិបាលក្រុង ស្រុក<br>មេឃុំ ចៅសង្កាត់ | ហត្ថលេខា និងត្រា<br>ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ហត្ថលេខា និងត្រា<br>ប្រធានរតនាគាររាជធានី ខេត្ត | ហត្ថលេខា<br>អ្នកធ្វើតារាង |

រាជធានី ខេត្ត........
ក្រុង ស្រុក ខណ្ឌ.....
ឃុំ សង្កាត់..........
លេខកូដ............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងសរុបចំនួនបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤

តារាងឧបសម្ព័ន្ធ÷ក១០

| បរិយាយ | សរុបរួមច្បាប់ដើមឆ្នាំ | អនុវត្តជាក់ស្តែង | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុបរួម | បុគ្គលិកអចិន្ត្រៃយ៍ | | | | | | | | បុគ្គលិកមិនអចិន្ត្រៃយ៍ | | | |
| | | | សរុប | ទីប្រឹក្សា ឬ ជំនួយការ | ក្រុមប្រឹក្សា | ប្រភេទ "ក" | ប្រភេទ "ខ" | ប្រភេទ "គ" | ភាពទំនេរពីការងារ | ជ្រើសរើសបុគ្គលិកថ្មី | សរុប | បុគ្គលិកជាប់កិច្ចសន្យា | មន្ត្រីភូមិ | បុគ្គលិកការិយាល័យប្រជាពលរដ្ឋ |
| **រដ្ឋបាលរាជធានី ខេត្ត**<br>-រដ្ឋបាលរាជធានី ខេត្ត<br>-មន្ទីរសុខាភិបាល | | | | | | | | | | | | | | |
| **រដ្ឋបាលក្រុង ស្រុក ខណ្ឌ**<br>-រដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>-ការិយាល័យអប់រំ<br>-ការផ្ទេរពាមុខងារ(អប់រំ) | | | | | | | | | | | | | | |
| **រដ្ឋបាលឃុំ សង្កាត់** | | | | | | | | | | | | | | |

*****កំណត់ចំណាំ÷ ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ត្រូវបូកបញ្ចូលទៅក្នុងតារាងបុគ្គលិកជាប់កិច្ចសន្យា។**

ហត្ថលេខា និងត្រា
អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
និងមេឃុំ ចៅសង្កាត់

ហត្ថលេខា
អ្នកធ្វើតារាង